ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៦១៣.០១៩.០១២ ប្រ.ការព័ត៌មាន

*ថ្ងៃសៅរ៍ ១១រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣*
*រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៩*

# សេចក្ដីប្រកាសព័ត៌មាន
## ស្ដីពី
## សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៩ របស់ធនាគារជាតិនៃកម្ពុជា

នៅថ្ងៃសៅរ៍ ១១រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៩ ធនាគារជាតិនៃកម្ពុជាបានរៀបចំសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៩ នៅអគារសែនសុខ ធនាគារជាតិនៃកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា។ សន្និបាតនេះមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាសរុបប្រមាណ ៥០០នាក់។

នៅឆមាសទី១នេះ ទោះបីជាកំណើនសេដ្ឋកិច្ចពិភពលោកបានបន្តថមថយល្បឿនបន្តិចដោយសារការថយចុះនៃសកម្មភាពពាណិជ្ជកម្មអន្តរជាតិ សេដ្ឋកិច្ចកម្ពុជានៅតែបន្តភាពរឹងមាំដែលគាំទ្រដោយកំណើនវិស័យកាត់ដេរ សំណង់ និងទេសចរណ៍ គួបផ្សំនឹងការកើនល្បឿនបន្តិចនៃវិស័យកសិកម្ម។ ជញ្ជីងទូទាត់ត្រូវបានប៉ាន់ស្មានថាមានស្ថានភាពល្អប្រសើរនិងបន្តមានអតិរេក ៥,៥% នៃផ.ស.ស. (៧៩១ លានដុល្លារអាមេរិក) ដែលគាំទ្រដោយភាពរឹងមាំនៃលំហូរចូលសុទ្ធគណនីហិរញ្ញវត្ថុ ទោះបីជាឱនភាពគណនីចរន្តកើនឡើងក៏ដោយ។ អតិរេកនេះនឹងបន្តរួមចំណែកបង្កើនទុនបម្រុងអន្តរជាតិដុល ដែលអាចធានាការនាំចូលទំនិញនិងសេវាសម្រាប់គ្រាបន្ទាប់បានប្រមាណ ៥ខែ ខ្ពស់ជាងកម្រិតអប្បបរមាចំនួន ៣ខែ ដែលប្រទេសកំពុងអភិវឌ្ឍន៍គួរមាន។

អត្រាអតិផរណាបន្តស្ថិតក្នុងកម្រិតទាប និងបានថយចុះមកត្រឹម ២% ដោយសារការអនុវត្តគោលនយោបាយរូបិយវត្ថុប្រកបដោយភាពប្រុងប្រយ័ត្ន តាមរយៈការរក្សាស្ថិរភាពអត្រាប្ដូរប្រាក់ (ក្នុងរង្វង់ ៤.០៣៨ រៀលក្នុងមួយដុល្លារអាមេរិក) និងការផ្គត់ផ្គង់រូបិយវត្ថុស្របតាមកំណើនសកម្មភាពសេដ្ឋកិច្ច។ រូបិយវត្ថុទូទៅ (M2) មានកំណើន ២១,៣% ប្រហាក់ប្រហែលនឹងអត្រាកំណើនឆមាសទី១ឆ្នាំមុន។ ប្រព័ន្ធធនាគារបន្តមានកម្រិតសន្ទនីយភាពខ្ពស់ ដោយសន្ទនីយភាពលើសជាដុល្លារអាមេរិកមានកម្រិត ៥៥% និងប្រាក់រៀលប្រមាណ ៣,៩ ដងនៃប្រាក់បម្រុងកាតព្វកិច្ច។ កម្រិត



ប្រអប់សំបុត្រលេខ ២៥, ទូរលេខ ៨៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

សន្ទនីយភាពខ្ពស់បានពង្រឹងភាពធន់នៃប្រព័ន្ធធនាគារដើម្បីទប់ទល់នឹងហានិភ័យនានាដែលអាចកើតឡើងជាយថាហេតុ។

ដើម្បីពង្រឹងប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ ការប្រើប្រាស់ប្រាក់រៀលត្រូវបានលើកកម្ពស់ជាបន្តបន្ទាប់ផ្អែកលើយន្តការទីផ្សារ។ ក្នុងបរិការណ៍នេះ មូលបត្រអាចជួញដូរបាន (NCDs) និងប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ត្រូវបានអភិវឌ្ឍ ដើម្បីស្រូបយក និងផ្គត់ផ្គង់ប្រាក់រៀលតាមតម្រូវការសេដ្ឋកិច្ច។ ការចេញផ្សាយ NCDs ចារឹកជាដុល្លារអាមេរិក មានចំនួន ១១ ប៊ីលានដុល្លារអាមេរិក ដែលបានកើនឡើងបន្តិច ខណៈដែលការចេញផ្សាយ NCDs ចារឹកជារៀលមានចំនួន ៣,៥ ទ្រីលានរៀលដែលបានថយចុះ ដោយសារគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានបង្កើនការផ្តល់ឥណទានជាប្រាក់រៀល។ ចំណែកប្រតិបត្តិការ LPCO ត្រូវបានធ្វើឡើងចំនួន ៨ លើក ដោយទំហំទឹកប្រាក់ដែលស្នើសុំដេញថ្លៃសរុបប្រមាណ ៤ ទ្រីលានរៀល កើនឡើង ១១ដង ធៀបនឹងឆមាសទី១ ឆ្នាំ២០១៨។

វិស័យធនាគារនិងហិរញ្ញវត្ថុបានបន្តអភិវឌ្ឍប្រកបដោយភាពរឹងមាំ និងបានចូលរួមចំណែកយ៉ាងសកម្មក្នុងការគាំទ្រ និងជំរុញកំណើនសេដ្ឋកិច្ច។ ទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានកើនឡើង ១៩,២% (ឆ្នាំលើឆ្នាំ) ស្មើនឹង ១៦៦% នៃផ.ស.ស. ឥណទាន ១០៣% និងប្រាក់បញ្ញើ ៩២% នៃផ.ស.ស។ គុណភាពសំពៀតឥណទានបន្តស្ថិតក្នុងស្ថានភាពល្អ ដោយអនុបាតឥណទានមិនដំណើរការមានកម្រិត ២,៣% សម្រាប់គ្រឹះស្ថានធនាគារ និង ១,១% សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ ដើម្បីរក្សាស្ថិរភាពហិរញ្ញវត្ថុឱ្យបានរឹងមាំ ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងការត្រួតពិនិត្យផ្អែកលើហានិភ័យនិងទស្សនៈអនាគត ការដាក់ចេញនូវវិធានការម៉ាក្រូនិងមីក្រូប្រុងប្រយ័ត្ន កិច្ចការពារអតិថិជន និងការយល់ដឹងផ្នែកហិរញ្ញវត្ថុរបស់សាធារណជន។

ដើម្បីគាំទ្រការរីកចម្រើនសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុក៏ត្រូវបានអភិវឌ្ឍជាលំដាប់ឱ្យកាន់តែមានប្រសិទ្ធភាព ជាពិសេសការធ្វើទំនើបកម្មប្រព័ន្ធទូទាត់ សំដៅលើកកម្ពស់សុវត្ថិភាព និងកាត់បន្ថយថ្លៃប្រតិបត្តិការ។ ប្រព័ន្ធសេវាទូទាត់រហ័ស (FAST System) ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការ និងប្រព័ន្ធខេមបូឌានស៊ើស្វីច (CSS) ត្រូវបានអភិវឌ្ឍ ដើម្បីអាចដាក់ឱ្យដំណើរការជាផ្លូវការក្នុងឆ្នាំ២០១៩នេះ។ ចំណែកប្រព័ន្ធទូទាត់ដុលភ្លាមៗ (RTGS) កំពុងត្រូវបានអភិវឌ្ឍ ដើម្បីសម្រួលនិងកាត់បន្ថយហានិភ័យចំពោះប្រតិបត្តិការទូទាត់សងប្រាក់តម្លៃធំអន្តរធនាគារ ជាពិសេសប្រតិបត្តិការទូទាត់ក្នុងទីផ្សារហិរញ្ញវត្ថុ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងអភិវឌ្ឍប្រព័ន្ធទូទាត់រាយតាមរយៈ QR កូដ និងប្រព័ន្ធផាត់ទាត់អេឡិចត្រូនិក។ ជាមួយនឹងការទាញយកផលពីបច្ចេកវិទ្យាហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាក៏បានដាក់ចេញនូវក្របខ័ណ្ឌបទប្បញ្ញត្តិសមស្របដើម្បីគ្រប់គ្រងការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុ សំដៅគាំទ្របរិយាប័ន្នហិរញ្ញវត្ថុឱ្យបានកាន់តែប្រសើរ និងរក្សាស្ថិរភាពហិរញ្ញវត្ថុ។

ប្រតិបត្តិការផ្ទេរប្រាក់ក្នុងនិងក្រៅប្រទេស ការផាត់ទាត់មូលប្បទានប័ត្រ និងបញ្ជាផ្ទេរឥណទានរបស់ស្ថាប័នរដ្ឋនិងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បានដំណើរការដោយរលូននិងមានប្រសិទ្ធភាព។ ចំពោះការគ្រប់គ្រងសាច់ប្រាក់ ធនាគារជាតិនៃកម្ពុជាបានបន្តតាមដាន និងវែង

ចែកសាច់ប្រាក់គ្រប់ប្រភេទនៅក្នុងចរាចរណ៍ ដើម្បីបំពេញតម្រូវការរបស់ប្រជាជនទូទាំងប្រទេស ព្រមទាំងបន្តការសហការរួមចំណែកក្នុងការកែទម្រង់និងគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ទន្ទឹមនឹងការរីកចម្រើនក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក) បានបន្តពង្រឹងប្រតិបត្តិការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម តាមរយៈការពង្រឹងការងារទទួល វិភាគ និងបញ្ជូនរបាយការណ៍ និងការចុះត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ស.ហ.ក បានលើកកម្ពស់ការយល់ដឹងពីបទប្បញ្ញត្តិនិងយន្តការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មដល់វិស័យសាធារណៈនិងឯកជន ព្រមទាំងបានបន្តពង្រឹងកិច្ចសហប្រតិបត្តិការទាំងក្នុងស្រុកនិងអន្តរជាតិ។ ទន្ទឹមនេះ ស.ហ.ក បានរៀបចំសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវយុទ្ធសាស្ត្រជាតិ ស្ដីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០១៩-២០២៣ ដែលជាមគ្គុទ្ទេសក៍រយៈពេលវែង។

ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងសមត្ថភាពជំនាញនិងឯកទេសកម្មជាប្រចាំ តាមរយៈការបណ្តុះបណ្តាលទាំងក្នុងនិងក្រៅប្រទេស ព្រមទាំងការសិក្សាតាមប្រព័ន្ធអនឡាញ។ កិច្ចសហប្រតិបត្តិការជាមួយបណ្តាស្ថាប័នអន្តរជាតិ និងធនាគារកណ្តាលនានា ទាំងក្នុងក្របខ័ណ្ឌទ្វេភាគី និងពហុភាគី ក៏ត្រូវបានពង្រឹងនិងពង្រីក ដើម្បីជំរុញសមាហរណកម្មហិរញ្ញវត្ថុក្នុងតំបន់និងពិភពលោកឱ្យកាន់តែស៊ីជម្រៅ ជាពិសេសការពង្រឹងបណ្តាញសុវត្ថិភាពហិរញ្ញវត្ថុតំបន់។

ឆ្លៀតក្នុងឱកាសនោះ ធនាគារជាតិនៃកម្ពុជា ក៏មានរៀបចំពិធីប្រគល់វិញ្ញាបនបត្រ និងផ្តល់រង្វាន់ជូនមន្ត្រីដែលបានប្រឡងជាប់កម្មវិធីបណ្តុះបណ្តាលឯកទេសកម្មសរុប ២១ រូប លើការត្រួតពិនិត្យធនាគារ (NBC-FSI Connect) ការវិភាគហិរញ្ញវត្ថុ (CFA) សវនកម្មផ្ទៃក្នុង (CIA) និងការវិភាគសេដ្ឋកិច្ច (FPP)។

សូមទំនាក់ទំនង៖
ធនាគារជាតិនៃកម្ពុជា
នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងសហប្រតិបត្តិការអន្តរជាតិ
ទូរសព្ទ៖ ០២៣ ៩៩០ ១៩៦
អ៊ីម៉ែល៖ nbccommunication@nbc.org.kh